CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 9 ខែមិថុនា ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# ហ្គ្រេក លូកាស បណ្ណារក្ស រដ្ឋកាលីហ្វ័រញ៉ា (California State Librarian Greg Lucas) បំពេញទស្សនកិច្ច នៅបណ្ណាល័យចំបង ប៊ីលលី ជែន ឃីង (Billie Jean King Main Library)

## *ដំណើរទស្សនកិច្ច រំលេចដោយ ការពិនិត្យមើល សណ្ឋានមុខងារសន្ទស្សន៍ស្វែងរក ជាភាសាខ្មែរ របស់ក្រុង ដែលជាករណីដំបូង នៅក្នុងប្រទេស សម្រាប់បណ្ណាល័យសាធារណៈ*

ឡុងប៊ិច, CA – នាពេលថ្មីៗ នេះ បណ្ណាល័យសាធារណៈ ឡុងប៊ិច (LBPL) បានរៀបចំពិធីទទួលដំណើរទស្សនកិច្ច របស់ហ្គ្រេក លូកាស បណ្ណារក្ស រដ្ឋកាលីហ្វ័រញ៉ា (California State Librarian Greg Lucas) រួមជាមួយ ស៊ីនឌី អាលែន (Cindy Allen) សមាជិកាក្រុមប្រឹក្សាក្រុងឡុងប៊ិច ព្រមទាំង តំណាង មកពីមូលនិធិ LBPL និងមិត្ត មកពីអង្គការ LBPL នៅ បណ្ណាល័យចំបង ប៊ីលលី ជែន ឃីង (Billie Jean King Main Library) ។ ដំណើរទស្សនកិច្ចនេះ មានរំលេចដោយ ការពិនិត្យមើល សណ្ឋានមុខងារសន្ទស្សន៍ស្វែងរក ជាភាសាខ្មែរ ដែលទើបតែបានបន្ថែម នាពេលថ្មីៗ នេះ ក្រោមមូលនិធិជំនួយ ចេញដោយបណ្ណាល័យរដ្ឋកាលីហ្វ័រញ៉ា និង ដែលជាករណីដំបូងមួយ នៃសណ្ឋានមុខងារប្រភេទនេះ នៅក្នុងប្រទេស ថែមទៅលើគ្រឿងជំនួយ ប្រកបដោយនវានុវត្តន៍ និងបែបសម្របលក្ខណៈ ផ្សេងៗ ទៀត របស់ LBPL ។

ស៊ីនឌី អាលែន (Cindy Allen) សមាជិកាក្រុមប្រឹក្សាក្រុងឡុងប៊ិច បានគូសបញ្ជាក់ថា «នេះពិតជាកិត្តិយសណាស់ ដែលបានស្វាគមន៍ បណ្ណារក្សរដ្ឋ របស់យើង មកកាន់ឡុងប៊ិច ហើយមានឱកាសបង្ហាញ ជូន បណ្ណាល័យចំបង ប៊ីលលី ជែន ឃីង (Billie Jean King Main Library) ដ៏ស្រស់ស្អាត របស់យើង និង ស្នាដៃការងារ ដ៏អស្ចារ្យ របស់បុគ្គលិកបណ្ណាល័យសាធារណៈ ឡុងប៊ិច របស់យើង ។»

ដំណើរទស្សនកិច្ចនេះ ជាដំណើរទស្សនកិច្ចដំបូង របស់បណ្ណារក្សរដ្ឋ មកកាន់ បណ្ណាល័យលេចធ្លោ របស់ក្រុង ដែលជាទីតាំងបណ្ណាល័យ នៅទីប្រជុំជន ដែលបានធ្វើការកែលំអឡើងវិញ ចាប់តាំងពីពេលបើកបម្រើសេវា ជូនសាធារណជន នៅខែកញ្ញា ឆ្នាំ 2019 មក ។ បណ្ណារក្សរដ្ឋ មើលខុសត្រូវលើ បណ្ណាល័យសាធារណៈ ជាង 1,100 កន្លែង នៅទូទាំងរដ្ឋ ហើយក្រុងមានកិត្តិយសណាស់ ដែលមានឱកាសរៀបចំពិធីទទួលដំណើរទស្សនកិច្ច ប្រកបដោយកិត្យានុភាពនេះ ។

ហ្គ្លេនដា វិលលាម (Glenda Williams) នាយក LBPL បានលើកឡើងថា «បណ្ណារក្សរដ្ឋ គឺជាសម្ព័ន្ធមិត្ត ដ៏អស្ចារ្យមួយ ក្នុងការផ្តល់មូលនិធិ សម្រាប់យើង ដើម្បីជំរុញម្ហូលគម្រោងបណ្ណាល័យ ដែលបម្រើជាអត្ថប្រយោជន៍ ដល់ប្រជាពលរដ្ឋឡុងប៊ិច ។» «ដោយមានការដាក់បន្ថែម សណ្ឋានមុខងារសន្ទស្សន៍ស្វែងរក

ជាភាសាខ្មែរ, ឥឡូវនេះ អ្នកអានភាសាខ្មែរ មានលទ្ធភាពចូលទៅរក កម្រងឯកសារជាភាសាខ្មែរ បាន យ៉ាងពេញលេញ ។»

បន្ថែមលើការបង្ហាញ ពីសណ្ឋានមុខងារសន្ទស្សន៍ស្វែងរក ជាភាសាខ្មែរ ដែលអនុវត្ត តាមរយៈប្រព័ន្ធ LBPL នៅ ខែមេសា, សេចក្តីរំលេចសង្ខេប អំពីដំណើរទស្សនាចរណ៍ ក៏មានរួមបញ្ចូល មជ្ឈមណ្ឌលសិក្សាលក្ខណៈគ្រួសារ, មជ្ឈមណ្ឌលបច្ចេកវិទ្យា បែបសម្របលក្ខណៈ, និងទីតាំងផលិតករ ពហុមុខងារ ហៅថា ស្ទូឌីយោ (The Studio) ដែលរួមមាន ម៉ាស៊ីនបោះពុម្ព 3D, ស្ទូឌីយោថតសម្លេង, ផ្នែកឯកសារសម្លេង និង ឯកសារផ្សាយ ឌីជីថល, និងផ្នែកជាច្រើនផ្សេងទៀត ផងដែរ ។

ហ្គ្រេក លូកាស (Greg Lucas) បណ្ណារក្សរដ្ឋកាលីហ្វ័រញ៉ា បាននិយាយថា «តែងតែមាន រឿងអស្ចារ្យ ជាច្រើន កើតមាន នៅបណ្ណាល័យឡុងប៊ិច ហើយជាការប្រសើរ ដែលមកជួបរឿងទាំងនេះ ដោយផ្ទាល់ ម្តងទៀត នោះ ។» «យើងខ្ញុំក៏មានមោទកភាព ក្នុងនាមជាដៃគូមួយ ក្នុងការជួយធ្វើឱ្យ សៀវភៅជាភាសាខ្មែរជាច្រើន កាន់តែមានលក្ខណៈអាចរកបាន សម្រាប់សហគមន៍ខ្មែរ ដ៏ធំ នៅក្នុងទីក្រុងនេះផងដែរ ។»

LBPL គឺជាបណ្ណាល័យសាធារណៈ ទីមួយ នៅក្នុងប្រទេស ដែលអនុវត្តសណ្ឋានមុខងារសន្ទស្សន៍ស្វែងរក ជាភាសាខ្មែរ ដែលទទួលបានមូលនិធិ ពីជំនួយ នៃច្បាប់បច្ចេកវិទ្យា និងសេវាបណ្ណាល័យ ដែលគ្រប់គ្រង ដោយបណ្ណាល័យរដ្ឋកាលីហ្វ័រញ៉ា ឆ្នាំ 2018 នេះ ។ បណ្ណាល័យ បានចាប់ដៃគូជាមួយ សហគមន៍សាមគ្គីកម្ពុជា ក្នុងអំឡុងពេលធ្វើការអភិវឌ្ឍ សណ្ឋានមុខងារសន្ទស្សន៍ស្វែងរក ដើម្បីប្រើប្រាស់ជំនាញភាសារបស់ពួកគេ និងធានថា មុខងារដំណើរការស្វែងរក អាចបំពេញបាន តាមសេចក្តីត្រូវការ សមស្រប របស់សហគមន៍ ។ កាលពីមុន ដើម្បីស្វែងរកសៀវភៅ នៅបណ្ណាល័យ ដែលមានរៀបកាតាឡុក ជាភាសាផ្សេងទៀត (លើកលែង ភាសាអេស្ប៉ាញ) ភ្ញៀវត្រូវស្វែងរក ក្នុងកាតាឡុក របស់បណ្ណាល័យ ជាភាសាអង់គ្លេស ជាមុនសិន ។ ដោយមានមុខងារដំណើរការថ្មី បច្ចុប្បន្ននេះ អ្នកអានអាចស្វែងរក អក្សរសាស្ត្រ ជាភាសាខ្មែរ តាមរយៈ ឈ្មោះអ្នកនិពន្ធ ចំណងជើង ឬប្រធានបទ បានដោយផ្ទាល់ហើយ ។ សណ្ឋានមុខងារសន្ទស្សន៍ស្វែងរកខ្មែរ អាចរកបាន តាមរយៈកាតាឡុក លើអ៊ីនធឺណែត របស់ LBPL នៅ longbeach.gov/library ហើយក៏អាចប្រើប្រាស់ ដោយផ្ទាល់ នៅក្នុងបណ្ណាល័យ បានផងដែរ ។

ដោយមានសៀវភៅ សម្រាប់មនុស្សធំ និងកុមារ ប្រមាណ 5,000 ក្បាល, LBPL មានកម្រងឯកសារ ជាភាសាខ្មែរ ច្រើនជាងគេ ក្នុងចំណោមបណ្ណាល័យសាធារណៈទាំងអស់ នៅសហរដ្ឋអាមេរិក ។

បណ្ណាល័យចំបង BJK បានបើកដំណើរការ កាលពីខែកញ្ញា ឆ្នាំ 2019 និងជាអគារទំហំ 92,500 ហ្វូតការ៉េ ដែលមានការបញ្ជាក់ទទួលស្គាល់ LEED លំដាប់មាស (92,500-square-foot LEED Gold-certified building) ។ ក្រោយពីបានបិទ មិនបម្រើសេវាជូនសាធារណជន តាំងពីខែមីនា ឆ្នាំ 2020 ដោយសារការដាក់កំហិត ផ្នែកសុខភាពសាធារណៈ ចំពោះ COVID-19 មក, នៅខែមុន LBPL ទើបតែបានបើក បណ្ណាល័យចំបង BJK, បណ្ណាល័យភូមិស្ថាន បេ៊យ សរ៍ (Bay Shore), ម៉ាកត្វេន (Mark Twain), និងមីសែល អូបាម៉ា (Michelle Obama) ឡើងវិញ ដោយកម្រិតចំនួនអ្នកចូល បន្ថែមលើការបន្តដំណើរការ LBPL To-Go ដែលជាសេវាបម្រើជូន សម្រាប់ការមកយក ដោយមិនប៉ះពាល់គ្នា និង Tech To-Go ដែលផ្តល់សេវាកម្ចី កុំព្យូទ័រក្រូមប៊ុក (Chromebook computer) និងដុំអ៊ីនធឺណែតអត់ខ្សែ (Mifi hotspot) ។

ខ្មែរ គឺជាភាសាផ្លូវការ របស់ប្រជាពលរដ្ឋកម្ពុជា ហើយជាភាសា និយាយជាទូទៅ ច្រើនបំផុត ដោយប្រជាពលរដ្ឋ មានដើមកំណើតខ្មែរ ។ នៅក្នុងសហរដ្ឋអាមេរិក ឡុងប៊ិច មានចំនួនប្រជាពលរដ្ឋ មកពីកម្ពុជា និងប្រជាពលរដ្ឋអាមេរិក ដើមកំណើតខ្មែរ ច្រើនជាងគេ ។ អ្នករស់រានមានជីវិត ពីរបបខ្មែរក្រហម បាន

ភៀសខ្លួន ពីប្រទេសកម្ពុជា មកសហរដ្ឋអាមេរិក នៅដើមទសវត្សរ៍ ឆ្នាំ1980 ក្នុងចំនួនច្រើនគួរសម ដែលរស់នៅជាជនភៀសខ្លួននៅទីនេះ ។

សម្រាប់ព័ត៌មានបន្ថែមទៀត អំពី LBPL រួមទាំង របៀបអបអរសាទរ ខួបទី 125 របស់បណ្ណាល័យ សូមចូលទៅ longbeach.gov/library ឬ តាម LBPL នៅ Facebook, Instagram និង Twitter ។

# # #